


# ការច្រូតកាត់ស្រូវ

## ❶ តើការច្រូតកាត់ជាអ្វី?

ការច្រូតកាត់គឺជាផ្នែកមួយនៃកិច្ចប្រតិបត្តិ ដើម្បីប្រមូលយកផ្នែកដែលមានប្រយោជន៍នៃដំណាំ។ ការប្រមូលផលគឺជាដំណើការនៃការប្រមូលនូវទិន្នផលដែលបានមកពីស្រែ ដោយរួមបញ្ចូលទាំងការច្រូតកាត់ ការប្រមូលកណ្តាប់ ការហាលសម្ងួត និងការសំអាត។ គោលបំណងនៃការច្រូតកាត់ គឺប្រមូលអោយបាននូវកំរិតអតិបរិមានូវគ្រាប់ស្រូវដែលមាននៅក្នុងស្រែ កាត់បន្ថយការបំផ្លាញទាំងបរិមាណស្រូវពីកត្តាផ្សេងៗ និងការខូតខាតនៃគុណភាពគ្រាប់។ ជាទូទៅការច្រូតកាត់ធ្វើឡើងដោយប្រើប្រាស់កណ្តៀវ ម៉ាស៊ីនច្រូតពាក់កណ្តាលស្វ័យប្រវត្ត និងម៉ាស៊ីនច្រូតកំបៃ (Combine harvester)។ លទ្ធផលនៃការសិក្សាមួយបានបង្ហាញថា ការបាត់បង់ផលស្រូវយ៉ាងហោចណាស់ក៏ ៣០ភាគរយ ដែរក្នុងអំឡុងពេលប្រមូលផល។ ដូចនេះបើយើងអនុវត្តបច្ចេកវិទ្យាក្រោយប្រមូលផលបានសមស្រប ដែលអាចជៀសវៀងបានពីការបាត់បង់នៅក្រោយពេលប្រមូលផល មានន័យថាយើងអាចបង្កើនបរិមាណផលពី ២៥ ទៅ ៣០ភាគរយ (Hall ១៩៧០)។

## ❷ ហេតុអ្វីបានជាពេលវេលាសមស្របសំរាប់ការប្រមូលផលមានសារសំខាន់?

ការប្រមូលផលស្រូវដែលធ្វើឡើងនៅពេលវេលាមួយ និងមានអត្រាសំណើមសមស្រប គឺបានផ្តល់អោយយើងនូវទិន្នផល អត្រាអង្ករដើម និងអត្រាដំណុះអតិបរិមា។ ដើម្បីអោយការច្រូតកាត់ធ្វើឡើងបានសមស្របបំផុត គេមិនត្រូវគិតតែពីអាយុកាល និងប្រភេទរបស់ដំណាំតែប៉ុណ្ណោះទេ គឺគេត្រូវពិនិត្យមើលផងដែរនូវកំរិតទុំជាក់ស្តែងរបស់ស្រូវក្នុងស្រែថែមទៀត។ ការប្រមូលផលយឺតពេកបណ្តាលអោយគ្រាប់ស្រូវជ្រុះខ្ចាត់ខ្ចាយក្នុងស្រែច្រើន តែបើស្ងួតជ្រុលពេកក៏ធ្វើឱ្យងាយប្រេះស្រាំ និងបាក់នៅពេលកិនជាអង្ករ។ ការប្រមូលផលឆាប់ពេកបណ្តាលអោយគ្រាប់ស្រូវជាច្រើននៅស្ទើរ ដែលធ្វើឱ្យថយចុះនូវបរិមាណ និងគុណភាពអង្ករដើម។

## ❸ វិធីសាស្រ្តក្នុងការច្រូតកាត់



វិធីសាស្រ្តសាមញ្ញក្នុងការច្រូតកាត់ស្រូវនៅតំបន់អាស៊ី គឺភាគច្រើនធ្វើឡើងដោយដៃ គេតែងយកកណ្តៀវជាឧបករណ៍សម្រាប់កាត់ដើមស្រូវ(ដើមនិងកួរស្រូវ) ដោយបន្សល់ទុកជើងជញ្រ្ជាំងនៅក្នុងស្រែប្រមាណពី ១៥ ទៅ ២៥សង់ទីម៉ែត្រ។ ដើមស្រូវដែលកាត់រួចហើយត្រូវបានប្រមូលចងជាកណ្តាប់ហើយហាលនៅក្នុងស្រែប្រមាណពី ២ ទៅ ៣ថ្ងៃ។ ការច្រូតកាត់ដោយដៃទាមទាកំលាំងពលកម្មពី ៤០ ទៅ ៨០ នាក់-ម៉ោង ក្នុងមួយហិកតា និងកំលាំងក្នុងការប្រមូលកណ្តាប់បន្ថែមទៀត។



ការច្រូតកាត់ អាចធ្វើឡើងផងដែរជាមួយម៉ាស៊ីនពាក់កណ្តាលស្វ័យប្រវត្ត តែវាមិនត្រូវបានប្រើប្រាស់ទូលំទូលាយនៅតំបន់អាស៊ីយើងឡើយ។ ប្រទេសមួយចំនួនគេប្រើឧបករណ៍ច្រូតបំពាក់ពីមុខត្រាក់ទ័រ និងឧបករណ៍ដែលបានអភិវឌ្ឍន៍ជាមួយម៉ាស៊ីនគោយន្តផ្សេងៗដែលធ្វើអោយការប្រមូលផលកាន់តែមានភាពងាយស្រួល ចំពោះម៉ាស៊ីនដែលមានទទឹងការងារ ១.៥ ម៉ែត្រ អាចប្រមូលផលបាន ២ ទៅ ៤ហិកតា/ថ្ងៃ។

ម៉ាស៊ីនច្រូតមួយចំនួនត្រូវបានគេអភិវឌ្ឍន៏ អោយកាន់តែមានភាពទំនើប និងកាន់តែងាយស្រួលក្នុងការប្រមូលផល ដោយរួមបញ្ចូលទាំងការកាត់ ហើយបញ្ជូនមកម៉ាស៊ីនបោក ញែកសំអាត រហូតដល់ដាក់នៅក្នុងបាវតែម្តង។ ប្រទេសមួយចំនួនដូចជា ឥណ្ឌា ចិន និង ថៃ បាននិងកំពុងប្រើប្រាស់ម៉ាស៊ីនច្រូតកាត់បែបនេះកាន់តែច្រើនឡើងៗ ព្រោះថាវាបានកាត់បន្ថយកំលាំងពលកម្មបានដល់កំរិតអតិបរិមា ហើយតាមការសិក្សាស្រាវជ្រាវចំពោះការបាត់បង់ គឺមានតិចជាងការច្រូតកាត់ដោយដៃ។

*(ឯកសារយោងពី IRRI និង វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា(CARDI)* ។



## ❹ តើពេលណាដែលយើងគួរធ្វើការច្រូតកាត់ស្រូវ?

- ត្រូវបង្ហូរទឹកចេញពីស្រែអោយបានពី ៧ ទៅ ១០ថ្ងៃ មុនពេលប្រមូលផល ឬនៅពេលដែលពិនិត្យឃើញថាស្រូវមានភាពទុំពេញលេញដែលបានផ្លូវពណ៌ពីបៃតងទៅលឿងទុំ ហើយគ្រាប់ស្រូវមិនទុំពេក និងមិនខ្ចីពេក ហើយគួរច្រូតកាត់នៅសំណើមពី ២០- ២៥% ។
- ត្រូវពិនិត្យអោយឃើញថា ដើមស្រូវ និងកួរស្រូវមានភាពស្ងួត និងមានភាពទុំពី ៨០-៨៥% ។
- ប្រសិនបើករណីដំណាំមានភាពសើមខ្លាំង ដូចជានៅពេលមានភ្លៀងធ្លាក់ រឺនៅពេលព្រឹកព្រលឹម គឺយើងគួរតែរង់ចាំឱ្យវាស្ងួតទឹកអស់សិនទើបធ្វើការច្រូតកាត់ ។



អត្រាសំណើមពី ២០-២៥ភាគរយ



ស្រូវទុំប្រមាណពី ៨០-៨៥ភាគរយ ក្នុងស្រែ




## ❺ ការណែនាំ

☞ ការប្រមូលផលយឺតពេកបណ្តាលឱ្យគ្រាប់ស្រូវជ្រុះខ្ចាត់ខ្ចាយក្នុងស្រែច្រើន ឬស្ងួតជ្រុលធ្វើអោយងាយប្រេះស្រាំនៅពេលបោកបែន ហើយគ្រាប់ស្រូវអាចបាក់នៅពេលកិនជាអង្ករ។ ការប្រមូលផលឆាប់ពេកបណ្តាយអោយគ្រាប់ស្រូវជាច្រើនទុំស្ទើរ ដែលធ្វើអោយថយចុះនូវបរិមាណ និងគុណភាពអង្ករដើមដែលកិនបាន។

☞ ដើម្បីអោយការច្រូតកាត់ស្រូវធ្វើឡើងបានសមស្របបំផុត គេមិនត្រូវគិតតែលើអាយុកាលរបស់ដំណាំដែលប្រែប្រួលទៅតាមប្រភេទពូជប៉ុណ្ណោះទេ ប៉ុន្តែគេក៏ត្រូវពិនិត្យមើលផងដែរនូវកំរិតទុំជាក់ស្តែងរបស់ស្រូវ។ តារាងខាងក្រោមនេះបង្ហាញនូវអត្រាសំណើម និងលក្ខណៈបញ្ជាក់ថាវាទុំពេញលេញ :

| **អត្រាសំណើម** | **លក្ខណៈរូបសាស្ត្រ** |
|---|---|
| ២០- ២៥ % | កួរស្រូវកោងចុះក្រោមដោយទម្ងន់របស់វា សំបកគ្រាប់មានពណ៌លឿងដាក់គ្រាប់ពេញ មិនទុំពេក (នាំឱ្យបាក់ស្រាំ) មិនខ្ចីពេក (ពណ៌នៅបៃតងនៅឡើយ) ។ |

សំរាប់ព័ត៌មានបន្ថែមសូមធ្វើការទាក់ទង ការិយាល័យវិស្វកម្មកសិកម្ម មជ្ឈមណ្ឌលបណ្តុះបណ្តាល និងព័ត៌មាន ការិយាល័យផែនការ សហប្រតិបត្តិការ និងពាណិជ្ជកម្ម នៃវិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៏កសិកម្មកម្ពុជានៅតាមបណ្តោយផ្លូវជាតិលេខ៣ សង្កាត់ប្រទះឡាង ខ័ណ្ឌដង្កោ រាជធានីភ្នំពេញ ឬតាមប្រអប់សំបុត្រលេខ០១ ភ្នំពេញ,ទូរស័ព្ទលេខ:(៨៥៥-២៣)២១៩ ៦៩៣-៤

ទូរសារលេខ: (៨៥៥-២៣ ) ២១៩ ៨០០ ទូរអក្ខរ: cardi@cardi.org.kh វែបសាយ: www.cardi.org.kh

Sbunna@cardi.org.kh TRIN@cardi.org.kh HUNYADANA@cardi.org.kh.kh